# ក្រុមការងារសង្គមស៊ីវិលកម្ពុជាប្រារព្ធទិវាសិទ្ធិមនុស្សអន្តរជាតិខួបលើកទី ៦៧ ក្រោមប្រធានបទស្តីពី "លើកកម្ពស់សេរីភាពខាងការបញ្ចេញមតិ"

ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៥ នេះ អង្គការសង្គមស៊ីវិលនៅកម្ពុជារៀបចំប្រារព្ធទិវាខួបលើកទី ៦៧ នៃ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស "ស.ស.ស.ម" ក្រោមប្រធានបទ "លើកកម្ពស់សេរីភាពខាងការបញ្ចេញមតិ" នៅរាជធានីភ្នំពេញ នៃព្រះរាជាណាចក្រកម្ពុជា។

ក្រៅពីមានការចូលរួមពីសាធារណៈជន យើងខ្ញុំបានអញ្ជើញសម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភាជាតិ ឯកឧត្តម ខៀវ កាញារិទ្ធិ រដ្ឋមន្ត្រីក្រសួងព័ត៌មាន ឯកអគ្គរដ្ឋទូតនៃប្រតិភូសហភាពអឺរ៉ុបប្រចាំកម្ពុជា ឯកអគ្គរាជទូតជប៉ុននិងសហរដ្ឋអាមេរិកប្រចាំកម្ពុជា តំណាងប្រចាំប្រទេសនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ដើម្បីចូលរួមក្នុងកម្មវិធីដ៏មានសារៈសំខាន់នេះ។

នៅក្នុងថ្ងៃជាប្រវត្តិសាស្ត្រនេះ សង្គមស៊ីវិលនៅប្រទេសកម្ពុជា សូមបង្ហាញនូវការដឹងគុណដល់អ្នកការពារសិទ្ធិមនុស្ស និងសកម្មជនសិទ្ធិមនុស្សទូទាំងសកលលោក ជាពិសេសអ្នកដែលបានចូលរួម និងពុះពារក្នុងការការពារសិទ្ធិមនុស្ស ហើយត្រូវជាប់ពន្ធនាគារ។

មហាសន្និបាតអង្គការសហប្រជាជាតិបានអនុម័ត ស.ស.ស.ម កាលពីថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨។ ស.ស.ស.ម បានកំណត់នូវសិទ្ធិមូលដ្ឋាន និងសេរីភាពយ៉ាងទូលាយដល់បុរស ស្ត្រី និងកុមារនៅលើសកលលោកដោយពុំមានការរើសអើងពូជសាសន៍ ពណ៌សម្បុរ ភេទ ជាតិពន្ធុ សាសនា វប្បធម៌ មតិនយោបាយ ឬមតិ ផ្សេងៗទៀត ដើមកំណើតជាតិ ឬសង្គម ទ្រព្យសម្បត្តិ និន្នាការភេទ និងស្ថានភាពដទៃទៀត។

យើងខ្ញុំជាអង្គការសង្គមស៊ីវិល ប្រារព្ធទិវាសិទ្ធិមនុស្សនេះឡើង ស្របពេលនឹងការបង្ហាញនូវការគាំទ្រចំពោះ ស.ស.ស.ម និងបង្ហាញនូវក្តីបារម្ភពាក់ព័ន្ធនឹងការបន្តរិតត្បិត និងការបំពានលើសេរីភាពមូលដ្ឋានខាងការជួបប្រជុំ ខាងការបង្កើតសមាគម និងខាងការបញ្ចេញមតិ។ យើងខ្ញុំមានបំណងចូលរួមសាមគ្គីគ្នាជាមួយអ្នកតស៊ូមតិខាងសិទ្ធិមនុស្ស សកម្មជន និងស្ថាប័នដែលធ្វើការការពារសិទ្ធិមនុស្សនៅទូទាំងប្រទេសកម្ពុជា។

យោងតាមមាត្រា១៩ នៃ ស.ស.ស.ម[1] និងមាត្រា៤១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣[2] រដ្ឋាភិបាលកម្ពុជាមានកាតព្វកិច្ចផ្លូវច្បាប់ក្នុងការគោរព និងការពារសេរីភាពខាងការបញ្ចេញមតិ ដែលជាសេរីភាព

---

[1] ដែលចែងថា *"មនុស្សគ្រប់រូបមានសិទ្ធិសេរីភាពក្នុងការមានមតិ និងការសម្តែងមតិ។ សិទ្ធិនេះរាប់បញ្ចូលទាំងសេរីភាពក្នុងការប្រកាន់មតិដោយគ្មានការជ្រៀតជ្រែក និងសេរីភាពក្នុងការស្វែងរកការទទួល និងការផ្សព្វផ្សាយព័ត៌មាន និងគំនិតនានាដោយគ្មានព្រំដែន ទោះតាមរយៈមធ្យោបាយសម្តែងមតិណាមួយក្តី។"*

[2] ដែលចែងថា *"ប្រជាពលរដ្ឋខ្មែរមានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារពត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ។ ជនណាក៏ដោយមិនអាចឆ្លៀតប្រើសិទ្ធិនេះ ដោយរំលោភនាំឲ្យមានប៉ះពាល់ដល់កិត្តិយសរបស់អ្នកដទៃ ដល់ទំនៀមទំលាប់ល្អរបស់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិបានឡើយ។"*

មូលដ្ឋានមួយទទួលស្គាល់ដោយច្បាប់ជាតិ និងអន្តរជាតិ។

យើងខ្ញុំទទួលស្គាល់កិច្ចប្រឹងប្រែងជាវិជ្ជមាន របស់រដ្ឋាភិបាលក្នុងវិស័យអភិវឌ្ឍន៍ជាច្រើន(ផ្នែកអប់រំ សុខភាពសាធារណៈ ចរន្តចំណូលថវិការរដ្ឋ និងអភិបាលកិច្ចនៅថ្នាក់មូលដ្ឋាន) និងតួអង្គជាច្រើន តាមរយៈការតែងតាំងអ្នកនាំពាក្យថ្មីពីគណបក្សជំទាស់នៅរដ្ឋសភា និងការបង្កើនប្រាក់បៀវត្សរ៍ដល់កងរាជអាវុធហត្ថ មន្ត្រីរាជការ និងកម្មកររោងចក្រ។

ទោះបីជាយ៉ាងណាក៏ដោយ យើងខ្ញុំមានការព្រួយបារម្ភជាខ្លាំងទៅលើការបន្តគាបសង្កត់លើសេរីភាពមូលដ្ឋាន រួមមានសេរីភាពខាងការបញ្ចេញមតិទាក់ទងនឹងការអនុម័តច្បាប់ជាច្រើននាពេលថ្មីៗនេះ រួមទាំងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល (ច្បាប់អង្គការសមាគម) និងច្បាប់បោះឆ្នោត។ ច្បាប់ទាំងនេះត្រូវបានអនុម័តដោយមានការចូលរួមពិគ្រោះយោបល់ជាមួយសង្គមស៊ីវិលឬអ្នកដែលពាក់ព័ន្ធតិចតួចឬគ្មានទាល់តែសោះ។ ស្រដៀងគ្នានេះ យើងក៏មានការព្រួយបារម្ភផងដែរថា សេចក្តីព្រាងច្បាប់ស្តីពីសហជីព ឧក្រិដ្ឋកម្មតាមប្រព័ន្ធបច្ចេកវិទ្យា និងទូរគមនាគមន៍ អាចនឹងត្រូវបានអនុម័តដោយពុំមានការពិគ្រោះយោបល់ត្រឹមត្រូវ។ ការត្រួតពិនិត្យឲ្យបានម៉ត់ចត់បង្ហាញពីលទ្ធភាពរបស់ច្បាប់ទាំងនេះ ក្នុងការរឹតត្បិតសេរីភាពមូលដ្ឋាន រួមមានទាំងសេរីភាពខាងការបញ្ចេញមតិ។

កិច្ចការចំបងរបស់យើងខ្ញុំក្នុងការការពារសិទ្ធិមនុស្ស គឺចងក្រងឯកសារអំពីការរំលោភបំពានសិទ្ធិមនុស្សដែលបន្តកើតឡើងនៅកម្ពុជា។ បច្ចុប្បន្ននេះ មានករណីរំលោភបំពានសិទ្ធិមនុស្សជាច្រើនកើតឡើងនៅទូទាំងប្រទេសកម្ពុជា រួមបញ្ចូលទាំងការបំពានលើរូបកាយ និងការបំពានតាមផ្លូវតុលាការ ចំពោះអ្នកដែលរិះគន់រដ្ឋាភិបាល។ ឧទាហរណ៍ករណីដែលកើតឡើងនាពេលថ្មីៗនេះរួមមានការប្រើអំពើហិង្សាទៅលើតំណាងរាស្ត្រពីរូបនៅមុខរដ្ឋសភា ការបំពានលើសិទ្ធិដីធ្លី រួមទាំងការរំលោភបំពានសិទ្ធិសមូហភាពលើដីធ្លី និងព្រៃឈើរបស់ជនជាតិដើមភាគតិច កង្វះខាតក្នុងការប្រកាន់ខ្ជាប់នូវស្តង់ដារសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ និងការបន្តបំពានសិទ្ធិការងារជាប្រព័ន្ធ។

ការវិវត្តថ្មីៗ នៃស្ថានភាពនយោបាយនៅកម្ពុជា ពាក់ព័ន្ធនិងសេរីភាពបញ្ចេញមតិហាក់បង្ហាញថាកម្ពុជាកំពុងឃ្លាតចាកឆ្ងាយពីគន្លងប្រជាធិបតេយ្យនិងកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីសស្តីពីកម្ពុជា។

ដោយសារតែការរំលោភសិទ្ធិមនុស្សនៅតែបន្តកើតមាន យើងខ្ញុំសូមអំពាវនាវឱ្យរាជរដ្ឋាភិបាលកម្ពុជា រដ្ឋសភាជាតិ ព្រឹទ្ធសភា និងតុលាការ ពិចារណាទៅលើវិធានការដូចខាងក្រោម៖

- អំពាវនាវដល់ថ្នាក់ដឹកនាំអំណាចគ្រប់លំដាប់ថ្នាក់ មេត្តារួបរួមគ្នាបើកចិត្តទទួលនូវមតិរិះគន់ដើម្បីភាពរុងរឿងនៃជាតិសាសន៍យើង នាំគ្នាលើកកម្ពស់សេរីភាពខាងការបញ្ចេញមតិនិងលទ្ធិប្រជាធិបតេយ្យ និងលើកស្ទួយវប្បធម៌សន្ទនានៅកម្ពុជា។
- បង្កើតយន្តការដ៏មានប្រសិទ្ធិភាពមួយ សម្រាប់ធ្វើការបញ្ជាក់ទៅលើច្បាប់ស្តីពីអង្គការសមាគម ដើម្បីផ្តល់សិទ្ធិគ្រប់គ្រាន់ក្នុងការអនុវត្តសេរីភាពខាងការបញ្ចេញមតិ ដែលនឹងផ្តល់អត្ថប្រយោជន៍ដល់សង្គមស៊ីវិល និងសង្គមកម្ពុជាទាំងមូល ដោយមានការលើកកម្ពស់សិទ្ធិមនុស្សតាមរយៈវគ្គបណ្តុះបណ្តាល និងសិក្ខាសាលានានា។
- ធ្វើវិសោធនកម្មច្បាប់បោះឆ្នោតដើម្បីធានាថា សេរីភាពខាងការបញ្ចេញមតិ និងការជួបប្រជុំត្រូវបានការពារយ៉ាងពេញលេញ ដល់អង្គការសង្គមស៊ីវិលឱ្យចូលរួមក្នុងដំណើរការបោះឆ្នោត ដោយគ្មានការជ្រៀតជ្រែកពីសំណាក់អាជ្ញាធរ។
- ទទួលយកយោបល់ និងធាតុចូលពីសង្គមស៊ីវិលមុនពេលអនុម័តច្បាប់នានា ជាពិសេសពិនិត្យមើលច្បាប់សហជីព ដើម្បីធានានូវការការពារសិទ្ធិរបស់កម្មករ និងបង្កើនលក្ខខណ្ឌការងារ និងស្តង់ដារស់នៅរបស់ពួកគេ និងច្បាប់ឧក្រិដ្ឋកម្មតាមប្រព័ន្ធបច្ចេកវិទ្យា ដើម្បីការពារសេរីភាពខាងការបញ្ចេញមតិ និងសិទ្ធិលើប្រព័ន្ធអ៊ីនធឺណែត។

- បញ្ឈប់ការបំពានតាមប្រព័ន្ធតុលាការចំពោះអ្នកការពារសិទ្ធិមនុស្ស អ្នកនយោបាយគណបក្សជំទាស់ សហជីព និងសកម្មជននានា។
- ដោះលែងដោយគ្មានលក្ខខណ្ឌចំពោះសកម្មជនដីធ្លី បរិស្ថាន និងនយោបាយ និងអ្នកការពារសិទ្ធិមនុស្សដែលកំពុងជាប់ពន្ធនាគារដោយសារតែសកម្មនិយម និងសកម្មភាពនយោបាយរបស់ពួកគេ។
- នាំយកជនដៃដល់ទាំងឡាយដែលបានប្រើហិង្សាមកលើ អ្នកសារព័ត៌មាន តំណាងរាស្ត្រគណបក្សប្រឆាំង កម្មកររោងចក្រ និងមន្ត្រីសហជីព និង
- ប្ដេជ្ញាបំពេញកាតព្វកិច្ចរបស់កម្ពុជាក្នុងការគោរពសិទ្ធិមនុស្ស និងបង្កើតយន្តការផ្ដល់សំណងសម្រាប់ជនរងគ្រោះនៅពេលមានអំពើហិង្សាកើតឡើង។

យើងសូមអំពាវនាវដល់ប្រជាពលរដ្ឋទាំងអស់ ឲ្យរួបរួមគ្នាក្នុងនាមជាម្ចាស់ប្រទេស អនុវត្តសិទ្ធិបញ្ចេញមតិដែលត្រូវបានធានាដោយរដ្ឋធម្មនុញ្ញកម្ពុជា តាមរយៈការចូលរួមយ៉ាងសកម្ម ក្នុងការតាមដានអ្នកនយោបាយ។ ជាចុងក្រោយចូលរួមលើកកម្ពស់សេរីភាពបញ្ចេញមតិនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៥

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង**


1. លោក ធន សារាយ ប្រធានគណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការ សមាគមការពារសិទ្ធិមនុស្សកម្ពុជា (CHRAC) និងជាប្រធានសម្របសម្រួលសមាគមអាដហុក ទូរស័ព្ទលេខ ០១៦ ៤៤០ ០៤៤
2. លោក សឿង សារឿន នាយកប្រតិបត្តិ គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា ទូរស័ព្ទលេខ ០១៦ ៩០០ ៥០៣
3. លោក តឹក វណ្ណារ៉ា នាយកប្រតិបត្តិ អង្គការមិនមែនរដ្ឋាភិបាលស្ដីពីកម្ពុជា ទូរស័ព្ទលេខ ០១២ ៧៩៣៤៨៩
4. លោក អាត់ ធន់ ប្រធានសហភាពការងារកម្ពុជា ទូរស័ព្ទលេខ ០១២ ៩៩៨ ៩០៦
5. លោកស្រី ដេត ចរិយា នាយិកាប្រតិបត្តិ អង្គការស្តារកម្ពុជា ទូរស័ព្ទលេខ ០១២ ៨០២ ៤៦០
6. លោក លោក សៅ វណ្ណសី នាយកប្រតិបត្តិ អង្គការគាំទ្រសហគមន៍ជនជាតិដើមភាគតិច ទូរស័ព្ទលេខ ០១២ ៨១៣ ៧៤៤
7. លោក ង៉ែត ធី នាយកប្រតិបត្តិ មជ្ឈមណ្ឌលកម្ពុជាដើម្បីសិទ្ធិកុមារ ទូរស័ព្ទលេខ ០១២ ៧២៩ ៨៩៥
8. លោក សួន ប៊ុនស័ក្តិ ប្រធានលេខាធិការដ្ឋាន គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃអង្គការ សមាគមការពារសិទ្ធិមនុស្សកម្ពុជា ទូរស័ព្ទលេខ ០៩២ ៣៤៤ ៣៥៧
9. លោកស្រី ចក់ សុភាព នាយិកាប្រតិបត្តិ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ០១១ ៩៤៣ ២១៣
10. លោក ងិត សៅវត្ថេ នាយកប្រតិបត្តិ អង្គការ ជនពិការកម្ពុជា ទូរស័ព្ទលេខ ០៩២ ៣៤៤ ៣៥៧
11. លោក សៀវ ភិរម្យ នាយកប្រតិបត្តិ អង្គការ សិទ្ធិលំនៅដ្ឋាន ទូរស័ព្ទលេខ ០១២ ៨៥២ ៣២៥